

# វ៉ែនតាដែលបានបាត់

ដោយ ខារ៉ូលីណា ម៉ាលដូណាដូ

*ដំណើររឿងពិតមកពីប្រទេសបូលីវី*





វាជាថ្ងៃដំបូងនៅឯសាលារៀន ។ អេនរេគ្រេ រំភើបខ្លាំងណាស់ ! ឥឡូវនេះគាត់នៅក្នុងថ្នាក់ទីមួយ ។ គាត់ជាក្មេងមាឌធំ !

ប៉ុន្តែនៅពេលគាត់ទៅដល់សាលា សាលាពិតជាធំ ហើយគួរឲ្យខ្លាច ទោះបីជាគាត់ធំក៏ដោយ ។ គាត់បានកាន់ដៃម៉ាក់ជាប់យ៉ាងណែន ។

« វានឹងមិនអីទេ » ម៉ាក់បានញញឹម ។ « ជម្រាបសួរដល់គ្រូរបស់កូនទៅ ! សូមធ្វើល្អដាក់មិត្តរួមថ្នាក់ ។ ហើយកុំភ្លេចទុកដាក់វ៉ែនតារបស់កូនឲ្យស្រួលបួលផង » ។

កាលពីមួយសប្ដាហ៍មុន អេនរេគ្រេទទួលបានវ៉ែនតាថ្មីដំបូងរបស់គាត់ ។ ឪពុកម្ដាយរបស់គាត់តែងតែរំឭកគាត់ឲ្យទុកដាក់វាឲ្យស្រួលបួល ។

ម៉ាក់បានត្រឡប់ទៅវិញ ។ « សូមឲ្យមានថ្ងៃដ៏ល្អ ! »

ប៉ុន្តែអេនរេគ្រេ *មិន* មានថ្ងៃល្អទេ ។ អ្វីមួយដែលអាក្រក់បានកើតឡើង !

គាត់បានរត់ទៅកាន់ម៉ាក់ បន្ទាប់ពីចេញពីសាលា ។ គាត់បានយំ « កូនបានបាត់វ៉ែនតារបស់កូនហើយ ! » « កូនបានរកមើលសព្វអស់ហើយ តែកូននៅតែមិនអាចរកវាឃើញទេ ! »







រចនារូបភាពដោយ ស៊ូសានណា ជីអូឌ្ស

« អូ ទេ ! » ម៉ាក់មានទឹកមុខព្រួយបារម្ភ ។ « ចូរយើងអធិស្ឋានទូលសុំជំនួយពីព្រះវរបិតាសួគ៌ » ។

គាត់បានសួរ « តើវានឹងបានទទួលចម្លើយពិតមែនឬ » ?

« សាកល្បងវាសិន ហើយចាំមើល ។ ម៉ាក់បាននិយាយថា ព្រះវរបិតាសួគ៌តែងតែព្រះសណ្ដាប់ឮការអធិស្ឋានរបស់យើង » ។

អេនរេគ្រេ និងម៉ាក់ពោលពាក្យអធិស្ឋាន ។ ពួកគេទូលសុំព្រះវរបិតាសួគ៌ដើម្បីជួយអេនរេគ្រេ ឲ្យរកឃើញវ៉ែនតារបស់គាត់ ។

នៅថ្ងៃបន្ទាប់នៅឯសាលា អេនរេគ្រេនៅតែសោកសៅ ។ បន្ទាប់មកក្មេងប្រុសម្នាក់បានដើរទៅរកគាត់ ។

« ខ្ញុំគិតថា វ៉ែនតានេះជារបស់ឯង » ។ ក្មេងប្រុសហុចវ៉ែនតាមួយឲ្យ ។ « ខ្ញុំបានឃើញវ៉ែនតានេះនៅទីលានបាល់ទាត់ » ។

អេនរេគ្រេបានយកវ៉ែនតាវិញ ។ នេះជាវ៉ែនតារបស់គាត់ ! គាត់មិនចង់ជឿទាល់តែសោះ ។

ក្រោយពីចេញពីសាលា គាត់បានរត់ទៅរកម៉ាក់ ហើយបានឱបគាត់យ៉ាងណែន ។

ម៉ាក់បាននិយាយថា « កូនបានរកឃើញវ៉ែនតារបស់កូនហើយ ! » « កូនប្រាកដជារីករាយណាស់ហើយដែលបានវាមកវិញ » ។

« បាទ កូនរីករាយណាស់ ! » អេនរេគ្រេបាននិយាយ ។ « ប៉ុន្តែកូនរីកតែសប្បាយចិត្តដោយសារតែអ្វីដែលកូនបានរៀន » ។

« ហើយនោះជាអ្វីទៅ » ?

អេនរេគ្រេបានញញឹមយ៉ាងធំ ។ « ការអធិស្ឋាន *ពិតជា* បានផលពិតមែន ! » ●